| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | សិក្សាសង្គ/វិទ្យាសាស្រ្ត |
| **ប្រធានបទ** | សិក្សាសង្គមៈ<br>ការយល់ដឹងអំពីអារម្មណ៍ខ្លួនឯង និងអ្នកដទៃៈ<br>(តាមរយៈទឹកមុខបែបកំប្លែង)<br>វិទ្យាសាស្រ្តៈ<br>សុខភាព និងអនាម័យ |
| **ចំណងជើងមេរៀន** | សិក្សាសង្គមៈ<br>សកម្មភាពសង្កេតៈ<br>អារម្មណ៍ទឹកមុខបែបកំប្លែង<br>វិទ្យាសាស្រ្តៈ<br>សកម្មភាពសង្កេតៈ<br>អនាម័យខ្លួនប្រាណ និងសុខភាព |
| **កម្រិត** | មធ្យម ៣០ នាទី |
| **គោលបំណង** | សិក្សាសង្គមៈ<br>-ឱ្យកុមារស្គាល់ពីអារម្មណ៍មួយចំនួន ដូចជា កំប្លែង។<br>វិទ្យាសាស្រ្តៈ<br>-ឱ្យកុមារទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម។ |
| **បំណិនសម្បទា** | សិក្សាសង្គមៈ<br>-បង្ហាញកាយវិការ ឬនិយាយអំពីក្ដីស្រឡាញ់ និងទំនាក់ទំនងជាមួយមនុស្សជុំវិញបែបទឹកមុខ |

| | |
|---|---|
| | កំប្លែងៗ។<br>វិទ្យាសាស្ត្រ៖<br>-សម្គាត់ខ្លួនប្រាណ អនាម័យ ក្រចកដៃ ជើង មាត់ធ្មេញ..។<br>-បង្ហាញពីអនាម័យសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ។ |
| **ចរិយាសម្បទា** | សិក្សាសង្គម៖<br>-សម្ដែងនូវកាយវិការ សហការ ចូលរួម ឈ្លាសវៃ រហ័សរហួនគោរពតាមការណែនាំ និងសប្បាយរីករាយ។<br>វិទ្យាសាស្ត្រ៖<br>-មានទម្លាប់រៀបចំអនាម័យខ្លួនប្រាណ សម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់។ |
| **គ្រូបង្រៀន** | អានសៀវភៅរឿងឱ្យសិស្សស្ដាប់ និងធ្វើកាយវិការតាមរយៈទឹកមុខ ទៅតាមសាច់រឿងបែបកំប្លែង។ |
| **កុមារ** | អង្គុយជាក្រុម ឬនៅកន្លែងរាងៗខ្លួន |
| **រៀបចំ** | ត្រូវសម្រេចចិត្តថាតើត្រូវសម្រេចចិត្តលេងជាក្រុមៗ ឬក៏ជាថ្នាក់តែម្ដង ។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|

| | | |
|---|---|---|
| 1. បង្ហាញក្មេងៗពីសៀវភៅរឿង ។<br>2. អានសៀវភៅម្តងទៀត។<br>3. បង្ហាញរូបភាពរបស់មករានិងនិយាយពីអារម្មណ៍ដែលខុសប្លែកពីគ្នាដែលមករាបានបង្ហាញនៅក្នុងសៀវភៅរឿង។<br>4. ចូរសួរក្មេងៗថាតើពួកគេនៅចាំបានទេថាអ្វីទៅដែលនៅក្នុងខ្លួនរបស់យើងដើម្បីការពារនិងប្រយុទ្ធប្រឆាំងនឹងមេរោគ?<br>5. សរសេរពាក្យ៖ ‹‹ប្រព័ន្ធភាពសាំុ›› នៅលើក្តារខៀនឱ្យពួកគេនិយាយតាមពាក្យហ្នឹងទាំងអស់គ្នា ។<br>6. ចូរសួរក្មេងៗថាតើនាងបាននិយាយថាអ្វីដែលអាចជួយដល់ប្រព័ន្ធភាពសាំុបាន?<br>7. ប្រាប់ក្មេងៗថាអ្នកមានវិធីផ្សេងទៀតក្នុងការជួយ | ក.ឱ្យក្មេងៗលើកដៃឡើងប្រសិនបើពួកគេចង់ធ្វើទឹកមុខសប្បាយ។<br>ហៅម្នាក់ឬ២នាក់ឡើងទៅខាងមុខនិងឱ្យពួកគេធ្វើទឹកមុខសប្បាយរីករាយបែបកំប្លែងៗតែម្តង។<br>ខ.បែងចែកក្មេងៗទៅជាក្រុមតូចៗនិងឱ្យពួកគេធ្វើទឹកមុខសប្បាយរីករាយកំប្លែងយ៉ាងសប្បាយរីករាយជាការស្រេច។<br>ការប្រែប្រួល៖<br>សុំឱ្យក្មេងៗនិយាយប្រាប់ពីសាច់រឿងកំប្លែងរបស់មិត្តភក្តិរបស់ពួកគេ។ | 1. ស្តាប់និងឆ្លើយសំណួរគ្រូរបស់អ្នក។<br>2. និយាយតាមពាក្យ ប្រព័ន្ធភាពសាំុ ។<br>3. ប្រសិនបើអ្នកចង់ធ្វើទឹកមុខកំប្លែងអ្នកត្រូវលើកដៃឡើងនិងត្រូវចាំគ្រូរបស់ហៅឈ្មោះរបស់អ្នក។<br>4. ប្រសិនបើលេងជាក្រុមនោះត្រូវចាំក្រុមរបស់ធ្វើទឹកមុខកំប្លែងម្នាក់ម្តងៗ<br>5. ផ្តល់ដំបូន្មានល្អៗទៅកាន់មិត្តរួមក្រុមឬមិត្តរួមថ្នាក់អំពីការធ្វើទឹកមុខកំប្លែងរបស់ពួកគេ។<br>6. ប្រសិនបើអ្នកបានរឿងរ៉ាវកំប្លែងៗពីនណាម្នាក់អ្នកអាចនិយាយប្រាប់មិត្តរួមក្រុមឬមិត្តរួមថ្នាក់របស់អ្នកបាន។ |

| | | |
|---|---|---|
| ដល់ប្រព័ន្ធភាពសាំុបាន។<br>គឺជាវិធីសប្បាយៗ កំប្លែងៗ។<br>8. ពន្យល់ថាប្រសិនបើអ្នកទាំងអស់គ្នាមានអារម្មណ៍សោកសៅនិងអារម្មណ៍ខឹង នោះប្រព័ន្ធភាពសាំុវាក៏មានអារម្មណ៍សោកសៅនិងខឹងដែរហើយពេលដែលវាមានអារម្មណ៍បែបហ្នឹងវាដំណើរការមិនល្អទេ។ បើប្រព័ន្ធភាពសាំុមានអារម្មណ៍ល្អនោះវាក៏ធ្វើការងារបានល្អដូចគ្នាដែរ។<br>9. ចូរសួរពួកគេ ‹‹តើពួកយើងធ្វើមុខសប្បាយរីករាយ យ៉ាងម៉េច?›› ‹‹តើយើងបង្ហាញទឹកមុខសប្បាយរីករាយខ្លាំងយ៉ាងម៉េច?›› (សើច)<br>10. ប្រាប់ពួកគេថាថ្ងៃនេះពួកគេនឹងធ្វើទឹកមុខសើចសប្បាយមួយចំនួនដោយធ្វើទឹកមុខបែបកំប្លែងៗតែម្តង ។ | | |

| | | |
|---|---|---|
| 11. ធ្វើទឹកមុខមួយដែលធ្វើឱ្យក្មេងៗទាំងអស់សើចបាន។<br>12. បន្តធ្វើសកម្មភាពមួយនេះដោយប្រើវិធីសាស្ត្រមួយក្នុងចំណោមទាំង២នេះ៖ | | |